**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការអភិវឌ្ឍន៍ស្ថាប័ននៃនិយ័តករមូលបត្រកម្ពុជា សម្រាប់រយៈពេល ៥ ឆ្នាំ (២០២១ - ២០២៥)

**បានទទួលការអនុម័តក្នុងកិច្ចប្រជុំក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**នាសម័យប្រជុំលើកទី ១១ អាណត្តិទី ១**

ថ្ងៃពុធ ២ រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

ត្រូវនឹងថ្ងៃទី១២ ខែតុលា ឆ្នាំ២០២២

រៀបចំដោយ

**និយ័តករមូលបត្រកម្ពុជានៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

ឆ្នាំ២០២២

## **អារម្ភកថា**

ក្រោមការដឹកនាំប្រកបដោយចក្ខុវិស័យវែងឆ្ងាយ និងមុតស្រួចរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រ ដើម្បីប្រែក្លាយកម្ពុជាជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ និងប្រទេសដែលមានចំណូលខ្ពស់ក្នុងឆ្នាំ២០៥០ ជាមួយនឹងសន្ទុះនៃកំណើនសេដ្ឋកិច្ចរបស់កម្ពុជាក្នុងអត្រា ៧% ជាមធ្យមក្នុងមួយឆ្នាំ។ រាជរដ្ឋាភិបាលបានដាក់ចេញនូវទិសដៅយុទ្ធសាស្ត្រច្បាស់លាស់ដូចមានកំណត់នៅក្នុង **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១៦-២០២៥** ដើម្បីជាមគ្គុទ្ទេសក៍ចង្អុលផ្លូវសម្រាប់អភិវឌ្ឍវិស័យមូលបត្រ និងវិស័យហិរញ្ញវត្ថុរយៈពេលវែង។ ក្នុងតួនាទីជំរុញការកៀរគរសាច់ប្រាក់ក្នុង និងក្រៅស្រុក ការបង្កើតការងារ ការបង្កើននូវកាលានុវត្តភាពវិនិយោគ និងការធ្វើពិពិធកម្មឧបករណ៍ហិរញ្ញវត្ថុ វិស័យមូលបត្រត្រូវបានកំណត់ជាវិស័យអាទិភាពមួយ ក្នុងការជួយជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយបរិយាបន្ន នវានុវត្តន៍ និងនិរន្តរភាព។

ដើម្បីបង្កើត និងអភិវឌ្ឍវិស័យមូលបត្រនៅកម្ពុជា គណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក.**) ដែលជានិយ័តករគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យមូលបត្រ ត្រូវបានបង្កើតឡើងក្រោមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ដែលត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧។ តាមរយៈច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារដែលត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ **គ.ម.ក.** ត្រូវបានប្តូរឈ្មោះជា និយ័តករមូលបត្រកម្ពុជា (**ន.ម.ក.**) ដែលស្ថិតក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ(**អ.ស.ហ.**)។ ក្នុងទិសដៅបន្តពង្រឹងតួនាទី និងការអភិវឌ្ឍស្ថាប័ន និងវិស័យមូលបត្រនៅកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ **ន.ម.ក.** បានតាក់តែង និងរៀបចំនូវ **ផែនការអភិវឌ្ឍន៍ស្ថាប័ននៃនិយ័តករមូលបត្រកម្ពុជាសម្រាប់រយៈពេល ៥ ឆ្នាំ (២០២១-២០២៥)** ដែលជាផែនទីបង្ហាញផ្លូវឆ្លើយតបនឹងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និងចក្ខុវិស័យរបស់រាជរដ្ឋាភិបាល។ គិតត្រឹមឆ្នាំ២០២១នេះ យើងមានក្រុមហ៊ុនបោះផ្សាយចំនួន ១៦ ក្រុមហ៊ុន ដែលមាន ៩ ក្រុមហ៊ុន ជាក្រុមហ៊ុនបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និង ៧ ក្រុមហ៊ុន ជាក្រុមហ៊ុនបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ ដែលក្រុមហ៊ុនទាំង ១៦ នេះបានប្រមូលសាច់ប្រាក់ចំនួន ២៨១,៧៩ លានដុល្លារអាមេរិក និងមានមូលធនូបនីយកម្មទីផ្សារចំនួន ៦,៥% ធៀបនឹងផលិតផលក្នុងស្រុកសរុបឆ្នាំ២០២១។ ទន្ទឹមនឹងនេះ **ន.ម.ក.** បានផ្តល់អាជ្ញាបណ្ណ/ការអនុញ្ញាតដល់ក្រុមហ៊ុនធ្វើអាជីវកម្មមូលបត្រចំនួន ១៨ ក្រុមហ៊ុន ក្រុមហ៊ុនធ្វើអាជីវកម្មឧបករណ៍និស្សន្ទចំនួន ៣៤ ក្រុមហ៊ុន និងក្រុមហ៊ុនធ្វើអាជីវកម្មគម្រោងវិនិយោគរួមចំនួន ៣០ ក្រុមហ៊ុន ព្រមទាំងបានផ្តល់ការអនុញ្ញាត/ការទទួលស្គាល់ដល់ក្រុមហ៊ុនផ្តល់សេវាក្នុងវិស័យមូលបត្រចំនួន ៣៥ ក្រុមហ៊ុន និងបានផ្តល់លេខអត្តសញ្ញាណវិនិយោគិនចំនួន ៣០,៧៩៨ ព្រមទាំងបានផ្តល់ការបណ្តុះបណ្តាល

ដល់សាធារណជន វិនិយោគិនសក្តានុពល និងក្រុមហ៊ុនបោះផ្សាយសក្តានុពល ប្រមាណជា ៦.០០០ រូប។ ក្រៅពីនេះ ដើម្បីពង្រឹងនូវសណ្តាប់ធ្នាប់ ទំនុកចិត្ត និងវិជ្ជាជីវៈជំនាញក្នុងទីផ្សារ **ន.ម.ក.** បានរៀបចំវគ្គបណ្តុះបណ្តាល និងការប្រឡង និងកម្មវិធីអប់រំវិជ្ជាជីវៈបន្តសម្រាប់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិចំនួន ២២ លើក ដែលមានអ្នកចូលរួមសរុបចំនួន ២.០៤៨ រូប។ ក្រោមកិច្ចខិតខំប្រឹងប្រែង និងការផ្តល់នូវកិច្ចសហការយ៉ាងល្អ **ន.ម.ក.** បានចុះអនុស្សរណៈនៃការយោគយល់គ្នា និងពហុអនុស្សរណៈនៃការយោគយល់គ្នាចំនួន ៤២ ជាមួយស្ថាប័នជាតិ និងអន្តរជាតិ។

ឆ្លៀតក្នុងឱកាសនេះ តាងនាមឱ្យក្រុមប្រឹក្សា **អ.ស.ហ.** និងរូបខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវមូលវិចារណ៍កោតសរសើរ និងវាយតម្លៃខ្ពស់ ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ **ន.ម.ក.** ក្នុងការរៀបចំ "**ផែនការអភិវឌ្ឍន៍ស្ថាប័ននៃនិយ័តករមូលបត្រកម្ពុជាសម្រាប់រយៈពេល ៥ ឆ្នាំ (២០២១-២០២៥)**" នេះប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងចក្ខុវិស័យវែងឆ្ងាយ ដែលបានឆ្លុះបញ្ចាំងពីស្មារតីបុរេសកម្មដែលមានផែនការច្បាស់លាស់ដើម្បីសម្រេចបាននូវសមិទ្ធផលរំពឹងទុកសម្រាប់រយៈពេល ៥ ឆ្នាំខាងមុខ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះ ឯកឧត្តម ***រស់ សីលវ៉ា*** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សា **អ.ស.ហ.** និងឯកឧត្តម **ម៉ី វ៉ាន់** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **អ.ស.ហ.** ព្រមទាំងថ្នាក់ដឹកនាំបច្ចេកទេសនៃ **អ.ស.ហ.** និងជាពិសេស ឯកឧត្តម **ស៊ូ សុជាតិ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃ **ន.ម.ក.** ព្រមទាំងក្រុមការងារបច្ចេកទេសទាំងអស់ដែលបានខិតខំរៀបចំ តាក់តែង និងសម្រិតសម្រាំងឯកសារដ៏មានសារៈសំខាន់នេះ។

ថ្ងៃ ចន្ទ ៧កើត ខែ កត្តិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី៣១ខែ តុលា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

មាតិកា


អារម្ភកថា....................................................................................................I

១. សេចក្តីផ្តើម...............................................................................................១

១.១. សាវតារ.................................................................................................១

១.២. រចនាសម្ព័ន្ធស្ថាប័ន ....................................................................................២

២. សមិទ្ធផល .................................................................................................៤

២.១. ការបង្កើតទីផ្សារមូលបត្រ .............................................................................៤

២.១.១. កាលបរិច្ឆេទសំខាន់ៗក្នុងវិស័យមូលបត្រកម្ពុជា .............................................៤

២.១.២. ការអនុម័តបទប្បញ្ញត្តិ.........................................................................៦

២.១.៣. ការផ្តល់អាជ្ញាបណ្ណ/ការអនុញ្ញាត/ការទទួលស្គាល់ ..........................................៦

២.២. ការធ្វើពិពិធកម្មទីផ្សារ ..................................................................................៨

២.២.១. ទីផ្សារកំណើន....................................................................................៨

២.២.២. ទីផ្សារមូលបត្របំណុល..........................................................................៨

២.២.៣. ទីផ្សារឧបករណ៍និស្សន្ទ..........................................................................៨

២.២.៤. ទីផ្សារគម្រោងវិនិយោគរួម .....................................................................៨

២.៣. ដំណើរការទីផ្សារមូលបត្រ............................................................................៩

៣. ការវាយតម្លៃតម្រូវការអភិវឌ្ឍស្ថាប័ន÷ បញ្ហាប្រឈម និងដំណោះស្រាយ ..................១៤

៣.១. ការវិភាគ និងវាយតម្លៃស្ថានភាពបច្ចុប្បន្ន (SWOT ANALYSIS) ..........................១៤

៣.១.១. ភាពខ្លាំង ..........................................................................................១៤

៣.១.២. ភាពខ្សោយ ........................................................................................១៤

៣.១.៣. ភាពប្រឈម........................................................................................១៤

៣.១.៤. កាលានុវត្តភាព.....................................................................................១៥

៣.២. ឧបសគ្គ បញ្ហាប្រឈម ភាពខ្វះចន្លោះ និងដំណោះស្រាយ........................................១៥

៤. ចក្ខុវិស័យ គោលបំណង និងគោលដៅ.................................................................១៧

៤.១. ចក្ខុវិស័យ ........ ១៧
៤.២. គោលបំណង ........ ១៧
៤.៣. គោលដៅ ........ ១៧
៥. ផែនការសកម្មភាពអភិវឌ្ឍស្ថាប័ន ........ ១៨
៥.១. គោលការណ៍នៃការរៀបចំសកម្មភាពការងារ ........ ១៨
៥.២. ក្របខណ្ឌយុទ្ធសាស្ត្រ ........ ១៨
៥.៣. សកម្មភាពការងារ ........ ១៩
៥.៣.១. សកម្មភាពជំរុញការអភិវឌ្ឍស្ថាប័ន ........ ១៩
៥.៣.១.១. ចង្កោមសកម្មភាពទី១÷ ការពង្រឹងអភិបាលកិច្ច ........ ១៩
៥.៣.១.២. ចង្កោមសកម្មភាពទី២÷ ការជំរុញការបោះផ្សាយលក់មូលបត្រ និងការគ្រប់គ្រងនិងត្រួតពិនិត្យតួអង្គពាក់ព័ន្ធក្នុងវិស័យមូលបត្រ ........ ២៣
៥.៣.១.៣. ចង្កោមសកម្មភាពទី៣÷ ការគាំពារវិនិយោគិនក្នុងវិស័យមូលបត្រ ........ ២៥
៥.៣.២. សកម្មភាពគាំទ្រការអភិវឌ្ឍស្ថាប័ន ........ ២៦
៥.៣.២.១. ចង្កោមសកម្មភាពទី១÷ ការពង្រឹង និងការពង្រីកកិច្ចការស្រាវជ្រាវ និងការអភិវឌ្ឍច្បាប់ និងបទប្បញ្ញត្តិ ........ ២៦
៥.៣.២.២. ចង្កោមសកម្មភាពទី២÷ ការពង្រឹង និងការពង្រីកការបណ្ដុះបណ្ដាល និងផ្សព្វផ្សាយ និងកិច្ចសហប្រតិបត្តិការ ........ ២៧
៦. យន្តការត្រួតពិនិត្យ និងការវាយតម្លៃ ........ ២៨
៦.១. ស្ថាប័នទទួលបន្ទុក ........ ២៨
៦.២. ការអនុវត្ត ការត្រួតពិនិត្យ និងការវាយតម្លៃ ........ ២៨
៧. សេចក្ដីសន្និដ្ឋាន ........ ២៩
៨. តារាងផែនការសកម្មភាព (MATRIX) ........ ៣០
ឧបសម្ព័ន្ធ÷ តារាងផែនការសកម្មភាពអភិវឌ្ឍស្ថាប័នសម្រាប់រយៈពេល ៥ ឆ្នាំ (២០២១-២០២៥) ........ ៣០

## ១. សេចក្តីផ្តើម

### ១.១. សាវតារ

សេដ្ឋកិច្ចកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងអត្រាកំណើនក្នុងរង្វង់ ៧% ក្នុងមួយឆ្នាំ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងភាពប៉ិនប្រសប់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។** ការអភិវឌ្ឍយ៉ាងឆាប់រហ័សបាននាំកម្ពុជាប្រែក្លាយមុខមាត់ពីប្រទេសមានចំណូលទាបទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប ទាំងនេះបានកើតចេញពីជម្រើស និងការអនុវត្តគោលនយោបាយដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាល ដោយការរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចតាមរយៈការអនុវត្តគោលនយោបាយរូបិយវត្ថុ និងគោលនយោបាយសារពើពន្ធប្រកបដោយភាពប្រុងប្រយ័ត្ន។

សមិទ្ធផលទាំងនេះ គឺមានការចូលរួមយ៉ាងសំខាន់ពីវិស័យហិរញ្ញវត្ថុ ដែលបាននិងកំពុងរីកចម្រើនយ៉ាងឆាប់រហ័សបន្ទាប់ពីរាជរដ្ឋាភិបាល បានដាក់ចេញនូវគំនិតផ្តួចផ្តើមដ៏សំខាន់ក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុរបស់កម្ពុជា តាមរយៈការអនុម័តនូវ "ចក្ខុវិស័យ និងផែនការអភិវឌ្ឍវិស័យហិរញ្ញវត្ថុឆ្នាំ២០០១-២០១០" និងត្រូវបានធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់ទៅជា "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥" និង "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥" ដើម្បីជាមគ្គុទ្ទេសក៍ចង្អុលផ្លូវសម្រាប់អភិវឌ្ឍវិស័យហិរញ្ញវត្ថុរយៈពេលវែង។ ជាមួយគ្នានេះ ដើម្បីឱ្យប្រព័ន្ធហិរញ្ញវត្ថុដំណើរការប្រកបដោយប្រសិទ្ធភាព ពិពិធភាព ចីរភាព និងបរិយាបន្ន ស្របតាមការវិវត្តយ៉ាងរហ័សនៃវិស័យហិរញ្ញវត្ថុ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ចក្ខុវិស័យក្នុងការបង្កើតវិស័យមូលបត្រនៅកម្ពុជា។

ជាចំណុចចាប់ផ្តើម ក្នុងឱកាសនៃកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ានបូកបី នៅទីក្រុងហ៊ីដេរ៉ាបាត (Hyderabad) ប្រទេសឥណ្ឌា នាថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៦ **ឯកឧត្តមកិត្តិបរិរក្សបណ្ឌិត គាត ឈន់** ជាមួយឯកឧត្តម នាយករដ្ឋមន្ត្រី **ជុក ស៊ូហាន់** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកូរ៉េ បានចុះអនុស្សរណៈនៃការយោគយល់គ្នាក្នុងគោលដៅរៀបចំ និងអភិវឌ្ឍវិស័យមូលបត្រនៅកម្ពុជា។ នាថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០៧ គម្រោងអភិវឌ្ឍទីផ្សារមូលបត្រនៅកម្ពុជា ត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។** ក្រោមគម្រោងអភិវឌ្ឍទីផ្សារមូលបត្រនេះ ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជនត្រូវបានរៀបចំ និងអនុម័តឱ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧, អនុក្រឹត្យលេខ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មការមូលបត្រកម្ពុជា និងអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

ត្រូវបានរៀបចំ និងអនុម័ត។ បន្ទាប់ពីការដាក់ឱ្យប្រើប្រាស់នូវច្បាប់ និងអនុក្រឹត្យទាំងនេះ គណៈកម្មការមូលបត្រកម្ពុជាត្រូវបានបង្កើតឡើង និងដាក់ឱ្យដំណើរការជាផ្លូវការនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ ហើយច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យមូលបត្រត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តជាបន្តបន្ទាប់។ បន្ទាប់ពីការបង្កើតគណៈកម្មការមូលបត្រកម្ពុជា វិស័យមូលបត្របានរីកចម្រើនយ៉ាងឆាប់រហ័ស និងបានចូលរួមចំណែកកាន់តែសំខាន់ក្នុងការពង្រឹងទំនុកចិត្ត និងជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ក៏ដូចជាសេដ្ឋកិច្ចជាតិទាំងមូល។

ទន្ទឹមនឹងនេះ ដោយមើលឃើញពីភាពរីកចម្រើននៃវិស័យហិរញ្ញវត្ថុមិនមែនធនាគារ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានសម្រេចបង្កើត **អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** តាមរយៈច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដែលត្រូវបានអនុម័ត និងប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១។ តាមរយៈច្បាប់នេះ **គណៈកម្មការមូលបត្រកម្ពុជា** ត្រូវបានប្តូរឈ្មោះទៅជា **និយ័តករមូលបត្រកម្ពុជា** (ហៅកាត់ថា **ន.ម.ក.**) ស្ថិតក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។ ប៉ុន្តែ មុខងារ និងតួនាទីរបស់ **ន.ម.ក.** នៅតែបន្តអនុវត្តដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មការមូលបត្រកម្ពុជា និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ក្នុងគោលបំណងពង្រឹង និងធានាប្រសិទ្ធភាពនៃការគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យហិរញ្ញវត្ថុមិនមែនធនាគារ រួមទាំងការលើកកម្ពស់ការអភិវឌ្ឍ និងប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ១.២. រចនាសម្ព័ន្ធស្ថាប័ន

**ន.ម.ក.** ត្រូវបានដឹកនាំដោយអគ្គនាយក ចំនួន ១ រូប អមដោយអគ្គនាយករងមួយចំនួន និងមាននាយកដ្ឋានចំណុះចំនួន ៦ រួមមាន÷ នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ, នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ, នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ, នាយកដ្ឋានកិច្ចការគតិយុត្ត, នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ និងនាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ។

# និយ័តករមូលបត្រកម្ពុជា (ន.ម.ក.)

- **អគ្គនាយក**
  - **អគ្គនាយករង**
    - **នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ**
      - ការិយាល័យរដ្ឋបាល និងបុគ្គលិក
      - ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ
      - ការិយាល័យគ្រប់គ្រងព័ត៌មានវិទ្យា
      - ការិយាល័យផែនការថវិកា
    - **នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ**
      - ការិយាល័យស្រាវជ្រាវ និងអភិវឌ្ឍន៍ទីផ្សារមូលបត្រ
      - ការិយាល័យបណ្តុះបណ្តាល និងផ្សព្វផ្សាយ
      - ការិយាល័យទំនាក់ទំនងអន្តរជាតិ
    - **នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ**
      - ការិយាល័យបោះផ្សាយមូលបត្រ និងឯកសារផ្តល់ព័ត៌មាន
      - ការិយាល័យអភិបាលកិច្ចសាជីវកម្ម
      - ការិយាល័យត្រួតពិនិត្យកិច្ចការគណនេយ្យ
      - ការិយាល័យគ្រប់គ្រងព័ត៌មានសាជីវកម្ម
    - **នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ**
      - ការិយាល័យត្រួតពិនិត្យប្រតិបត្តិការទីផ្សារមូលបត្រ
      - ការិយាល័យត្រួតពិនិត្យប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ
      - ការិយាល័យត្រួតពិនិត្យសេវារក្សាទុកមូលបត្រ
    - **នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ**
      - ការិយាល័យគ្រប់គ្រងអាជីវកម្មគម្រោងវិនិយោគរួម និងអាជីវកម្មឧបករណ៍និស្សន្ទ
      - ការិយាល័យសម្រប-សម្រួល និងអាជ្ញាបណ្ណ
      - ការិយាល័យត្រួតពិនិត្យលើឯកសារ
      - ការិយាល័យត្រួតពិនិត្យដល់ទីកន្លែង
    - **នាយកដ្ឋានកិច្ចការគតិយុត្ត**
      - ការិយាល័យពង្រឹងការអនុវត្តច្បាប់ និងនីតិកម្ម
      - ការិយាល័យស៊ើបអង្កេត
      - ការិយាល័យទទួលពាក្យបណ្តឹង និងដោះស្រាយវិវាទ

# ២. សមិទ្ធផល

## ២.១. ការបង្កើតទីផ្សារមូលបត្រ

### ២.១.១. កាលបរិច្ឆេទសំខាន់ៗក្នុងវិស័យមូលបត្រកម្ពុជា

**២០០១**

-២៤ សីហា អនុម័តចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០១

**២០០៦**

-០៤ ឧសភា ចុះអនុស្សរណៈនៃការយោគយល់គ្នាលើការលើកស្ទួយដល់ការអភិវឌ្ឍវិស័យមូលបត្រនៅកម្ពុជារវាងប្រទេសកម្ពុជា និងកូរ៉េ

-២០ វិច្ឆិកា ចុះអនុស្សរណៈនៃការយោគយល់គ្នា ស្ដីពីកិច្ចសហប្រតិបត្តិការក្នុងការបង្កើតទីផ្សារមូលបត្រ រវាងឯកឧត្តមកិត្តិបរិវក្សបណ្ឌិត **គាត ឈន់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា និងផ្សារមូលបត្រកូរ៉េ

**២០០៧**

-០៦ កញ្ញា ប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនូវគម្រោងបង្កើតទីផ្សារមូលបត្រនៅកម្ពុជាក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

-១៩ តុលា ដាក់ឱ្យអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ដោយព្រះរាជក្រមរបស់ សម្ដេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

**២០០៨**

-២៣ កក្កដា ដាក់ឱ្យអនុវត្តអនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា

**២០០៩**

-១៨ មីនា តែងតាំងសមាសភាពគណៈកម្មការមូលបត្រកម្ពុជា ដែលមានឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាប្រធាន

-២៣ មីនា ចុះហត្ថលេខាលើកិច្ចព្រមព្រៀងរួមទុនស្ដីពីការបង្កើតផ្សារមូលបត្រកម្ពុជា រវាងផ្សារមូលបត្រកូរ៉េ (KRX) និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា

-២៩ មេសា សម្ពោធដាក់ឱ្យប្រើប្រាស់ទីស្នាក់ការបណ្ដោះអាសន្ននៃ **គ.ម.ក.**

**២០១០**

-ផ្ដល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនមូលបត្រ

-ផ្ដល់ការអនុញ្ញាតដល់ផ្សារមូលបត្រកម្ពុជា ធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ

**២០១១**

-១១ កក្កដា សម្ពោធដាក់ឱ្យដំណើរការផ្សារមូលបត្រកម្ពុជា

**២០១២**

-១៨ មេសា ចុះបញ្ជីមូលបត្រកម្មសិទ្ធិលើកដំបូងនៅផ្សារមូលបត្រកម្ពុជា ជាប្រវត្តិសាស្ត្រ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** (សារវីដេអូ)

-ចូលជាសមាជិកវេទិកាទីផ្សារមូលធនអាស៊ាន ASEAN Capital Market Forum (ACMF)

**២០១៥**

-០២ កក្កដា អនុម័តលើការអនុញ្ញាតឱ្យមានការជួញដូរឧបករណ៍និស្សន្ទ
-បង្កើតទីផ្សារកំណើន

**២០១៦**

-ផ្តល់អាជ្ញាបណ្ណ និងដាក់ឱ្យដំណើរការទីផ្សារឧបករណ៍និស្សន្ទ

**២០១៧**

-១៧ សីហា អនុម័តប្រកាសស្តីពីការបោះផ្សាយមូលបត្របំណុល
-២៦ ធ្នូ អនុញ្ញាតឱ្យមានវិធីសាស្ត្រជួញដូរតាមការចរចារ
-១៥ កញ្ញា ក្លាយជាសមាជិកសហការីនៃអង្គការគណៈកម្មការមូលបត្រអន្តរជាតិ (IOSCO)

**២០១៨**

-០៦ ធ្នូ ផ្តល់ការអនុញ្ញាតឱ្យក្រុមហ៊ុនចុះបញ្ជីលក់មូលបត្របំណុលជាសាធារណៈលើកទី១នៅផ្សារមូលបត្រកម្ពុជា
-២៩ ឧសភា ដាក់ចេញប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងអាជីវកម្មគម្រោងវិនិយោគរួម
-១៤ ធ្នូ ចុះពហុអនុស្សរណៈនៃការយោគយល់គ្នាស្តីពី “កិច្ចសហប្រតិបត្តិ និងការអភិវឌ្ឍទីផ្សារមូលធនក្នុងអនុតំបន់ទន្លេមេគង្គ-Mekong Capital Markets Cooperation-MCMC”

**២០១៩**

-២៥ មិថុនា ដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវប្រព័ន្ធជួញដូរចល័ត (Mobile Trading System)
-១៩ សីហា អនុញ្ញាតក្នុងការបង្កើនម៉ោងជួញដូរ ពីម៉ោង ៨:០០ ព្រឹក ដល់ ម៉ោង ៣:០០ រសៀល

**២០២០**

-០៥ ឧសភា បានដាក់ចេញប្រកាសស្តីពី ការបោះផ្សាយលក់មូលបត្របំណុលសម្រាប់វិនិយោគិនគុណវុឌ្ឍិ
-២៦ ធ្នូ អនុម័តច្បាប់ស្តីពីមូលបត្ររដ្ឋ

**២០២១**

-១៦ មករា បង្កើតអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
-២៤ មិថុនា ផ្តល់ការអនុញ្ញាតការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិជាសាធារណៈក្នុងទីផ្សារកំណើនលើកទី១នៅផ្សារមូលបត្រកម្ពុជា
-១៦ មិថុនា ដាក់ឱ្យដំណើរការការស្នើសុំលេខអត្តសញ្ញាណវិនិយោគិនតាមប្រព័ន្ធអនឡាញ
-កក្កដា ដាក់ចេញគោលការណ៍ណែនាំលម្អិតសម្រាប់ការបោះផ្សាយសញ្ញាបណ្ណបៃតងជាភាសាខ្មែរ

### ២.១.២. ការអនុម័តបទប្បញ្ញត្តិ

ក្នុងនាមជាអាជ្ញាធរក្នុងវិស័យមូលបត្រ **ន.ម.ក.** បានចាប់ផ្ដើមរៀបចំ និងអនុម័តនូវបទប្បញ្ញត្តិចាំបាច់សម្រាប់ដំណើរការទីផ្សារមូលបត្រនៅកម្ពុជាប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងសណ្ដាប់ធ្នាប់។ ច្បាប់ចំនួន ២ អនុក្រឹត្យចំនួន ៧ ប្រកាសចំនួន ៧៦ និងគោលការណ៍ណែនាំ និងទម្រង់លិខិតផ្លូវការជាច្រើនត្រូវបានរៀបចំ ពិនិត្យ អនុម័ត និងដាក់ឱ្យអនុវត្ត។ **ន.ម.ក.** បានរៀបចំកិច្ចប្រជុំរបស់ខ្លួនក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមកិត្តិបវិរក្សបណ្ឌិត គាត ឈន់ ប្រធាន គ.ម.ក.** (អាណត្តិទី១) និងក្រោមការដឹកនាំបន្តដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន** (អាណត្តិទី២ មកដល់បច្ចុប្បន្ន) សរុបចំនួន ៦២ លើក គិតមកត្រឹមការបង្កើតអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារក្នុងឆ្នាំ២០២១។

### ២.១.៣. ការផ្ដល់អាជ្ញាបណ្ណ/ ការអនុញ្ញាត/ ការទទួលស្គាល់

តាមរយៈប្រកាសលេខ ០០៩ គមក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្ដីពីការផ្ដល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ **ន.ម.ក.** បានផ្ដល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនពាណិជ្ជករមូលបត្រ ក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ និងក្រុមហ៊ុនទីប្រឹក្សាវិនិយោគ ដែលជាតួអង្គសំខាន់នៅក្នុងការដាក់ឱ្យដំណើរការទីផ្សារមូលបត្រ។ គិតចាប់ពីឆ្នាំ ២០១០ រហូតមកដល់ឆ្នាំ ២០២១ នេះ **ន.ម.ក.** បានផ្ដល់អាជ្ញាបណ្ណ/ ការអនុញ្ញាតដល់ក្រុមហ៊ុនធ្វើអាជីវកម្មមូលបត្រចំនួន ១៦ ក្រុមហ៊ុន។

តាមរយៈប្រកាសលេខ ០១១ គមក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីការផ្ដល់ការអនុញ្ញាតធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ **ន.ម.ក.** បានផ្ដល់ការអនុញ្ញាតដល់ផ្សារមូលបត្រកម្ពុជា ដែលជាសហគ្រាសសាធារណៈ ក្នុងនោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្ពុជាកាន់កាប់ ៥៥% និងផ្សារមូលបត្រកូរ៉េកាន់កាប់ ៤៥% ធ្វើជាប្រតិបត្តិករទាំង៣ នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០។

តាមរយៈប្រកាសលេខ ០០១ គមក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ ស្ដីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ បានក្លាយជាក្រុមហ៊ុនទី១ ក្នុងប្រវត្តិសាស្ត្ររបស់កម្ពុជាដែលបានបោះផ្សាយ និងចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិជាសាធារណៈនៅផ្សារមូលបត្រកម្ពុជា។

**ន.ម.ក.** បានផ្ដល់អាជ្ញាបណ្ណ ការអនុញ្ញាត និងការទទួលស្គាល់ដល់ក្រុមហ៊ុនផ្សេងៗទៀតដូចខាងក្រោម÷

| អាជ្ញាបណ្ណ/ការអនុញ្ញាត/ការទទួលស្គាល់ | ការផ្ដល់អាជ្ញាបណ្ណ/ការអនុញ្ញាត/ការទទួលស្គាល់ គិតត្រឹម២០២១ |
|---|---|
| ក្រុមហ៊ុនមូលបត្រ | ១២ |
| ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ | ៣ |
| ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ | ១ |
| ក្រុមហ៊ុនចែកចាយលក់មូលបត្រ | ២ |
| ក្រុមហ៊ុនសមភាគីកណ្តាល | ៥ |
| ឈ្មួញជើងសាឧបករណ៍និស្សន្ទ | ២៩ |
| ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ | ១៥ |
| ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស | ១២ |
| ក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង | ៣ |
| ក្រុមហ៊ុនអភិបាលមូលនិធិ | ១ |
| ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យមូលបត្រ | ៨ |
| ក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់ | ១៥ |
| ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ | ៣ |
| ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និង ភ្នាក់ងារទូទាត់ | ៣ |
| ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ | ៦ |
| ភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល | ១ |
| ក្រុមហ៊ុនផ្តល់សេវាបកប្រែ | ១ |
| **សរុប** | **១២០** |

## ២.២. ការធ្វើពិពិធកម្មទីផ្សារ

ដើម្បីជំរុញនូវការអភិវឌ្ឍទីផ្សារមូលបត្រ ក៏ដូចជាការអភិវឌ្ឍសេដ្ឋកិច្ចជាតិ តាមរយៈការជំរុញនូវការកៀរគរមូលធនដែលមាននៅក្នុងទីផ្សារប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព និងវិនិយោគិនទទួលបាននូវការការពារ **ន.ម.ក.** បានបង្កើតទីផ្សារបន្ថែមជាបន្តបន្ទាប់ រួមមានទីផ្សារកំណើន ទីផ្សារមូលបត្របំណុល ទីផ្សារឧបករណ៍និស្សន្ទ និងទីផ្សារគម្រោងវិនិយោគរួម។

### ២.២.១. ទីផ្សារកំណើន

ដើម្បីជំរុញការអភិវឌ្ឍវិស័យមូលបត្រ និងចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការជំរុញការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា ក្នុងឆ្នាំ២០១៥ **ន.ម.ក.** បានដាក់ឱ្យដំណើរការទីផ្សារកំណើន ដែលជាទីផ្សារសម្រាប់ការចុះបញ្ជីលក់មូលបត្ររបស់សហគ្រាសធុនតូច និងមធ្យមតាមរយៈការធ្វើវិសោធនកម្មប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងអនុម័តដាក់ឱ្យអនុវត្តនៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥។ តាមរយៈប្រកាសនេះ ផ្សារមូលបត្រកម្ពុជាបានបែងចែកទីផ្សារមូលបត្រកម្មសិទ្ធិជាពីរប្រភេទគឺ ទីផ្សារគោល និងទីផ្សារកំណើន។

### ២.២.២. ទីផ្សារមូលបត្របំណុល

ជាការឆ្លើយតបទៅនឹងតម្រូវការទីផ្សារ និងការបង្កើតជម្រើសនូវយន្តការហិរញ្ញប្បទាន **ន.ម.ក.** បានដាក់ឱ្យដំណើរការទីផ្សារមូលបត្របំណុលតាមរយៈការរៀបចំ និងអនុម័តដាក់ឱ្យអនុវត្តប្រកាសលេខ ០០៩/១៧ គ.ម.ក./ប្រ.ក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៧ ស្តីពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ។

### ២.២.៣. ទីផ្សារឧបករណ៍និស្សន្ទ

ដោយពិនិត្យឃើញពីតម្រូវការនៃទីផ្សារ និងដើម្បីរក្សាសណ្តាប់ធ្នាប់ទីផ្សារ និងការពារវិនិយោគិន **ន.ម.ក.** បានដាក់ឱ្យដំណើរការទីផ្សារឧបករណ៍និស្សន្ទនៅឆ្នាំ២០១៦ តាមរយៈការរៀបចំ និងអនុម័តដាក់ឱ្យអនុវត្តប្រកាសលេខ ០០៤/១៥ គ.ម.ក./ប្រ.ក ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងការជួញដូរឧបករណ៍និស្សន្ទ។

### ២.២.៤. ទីផ្សារគម្រោងវិនិយោគរួម

ដោយសម្លឹងឃើញពីសក្តានុពលនៃទីផ្សារគម្រោងវិនិយោគរួមក្នុងការជួយជំរុញការអភិវឌ្ឍទីផ្សារមូលបត្រនៅកម្ពុជា និងសេដ្ឋកិច្ចជាតិ **ន.ម.ក.** បានអនុម័តដាក់ឱ្យអនុវត្តប្រកាសលេខ ០០៣/១៨ គ.ម.ក./ប្រ.ក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងអាជីវកម្មគម្រោងវិនិយោគរួម ដើម្បីបង្កើតតួអង្គសំខាន់ៗនៃអាជីវកម្មគម្រោងវិនិយោគរួម រួមមានក្រុមហ៊ុនគ្រប់គ្រងមូល-

និធិ ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស ក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង និងក្រុមហ៊ុនអភិបាលមូលនិធិ។

### ២.៣. ដំណើរការទីផ្សារមូលបត្រ

គិតត្រឹមឆ្នាំ ២០២១ **ន.ម.ក.** បានផ្តល់ការអនុញ្ញាតឱ្យបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈដល់ក្រុមហ៊ុនចំនួន ៩ និងបានប្រមូលសាច់ប្រាក់សរុបចំនួន ១១៨,៧៩ លានដុល្លារអាមេរិក និងមានទំហំជួញដូរសរុបចំនួន ១០៥.៩៩៣.២៦៧ ភាគហ៊ុន ដែលគិតជាតម្លៃជួញដូរគឺប្រហាក់ប្រហែលនឹង ១៦៣,១៤ លានដុល្លារអាមេរិក។ ជាមួយគ្នានេះ **ន.ម.ក.** ក៏បានផ្តល់លេខអត្តសញ្ញាណវិនិយោគិនចំនួន ៣០.៧៩៨ ដែលក្នុងនោះមានស្ត្រីចំនួន ៣៣,៧% វិនិយោគិនរូបវន្តបុគ្គលចំនួន ៣០.៦៤៩ និងសញ្ជាតិបរទេសចំនួន ៤.៤១៨។

| ល.រ | ឈ្មោះក្រុមហ៊ុន | វិស័យ/ អាជីវកម្ម | ចំនួនមូលបត្រកម្មសិទ្ធិ ដែលបានបោះផ្សាយ | ចំនួនសាច់ប្រាក់ដែលប្រមូល បានពីការបោះផ្សាយ | |
|---|---|---|---|---|---|
| | | | | រៀល | ដុល្លារ |
| **ទីផ្សារកំណើន** | | | | | |
| ១ | ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក | សំណង់ និងវិស្វកម្ម | ៦.៤៦១.៥៣៨ | ១៥.៣៧៨.៤៦០.៤៤០ | ៣.៨៤៤.៦១៥ |
| ២ | ជេអេស លែន ភីអិលស៊ី | សាងសង់ខុនដូរ | ៨.២៨១.០០០ | ១៥.៧៣៣.៩០០.០០០ | ៣.៩៣៣.៤៧៥ |
| **ទីផ្សារគោល** | | | | | |
| ៣ | រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ | ផលិត និងចែកចាយទឹក | ១៣.០៤៥.៩៧៥ | ៨២.១៨៩.៦៤២.៥០០ | ២០.៥៤៧.៤១១ |
| ៤ | ហ្រ្គេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី | វាយនភណ្ឌ សំលៀកបំពាក់ | ៨.០០០.០០០ | ៧៧.១២០.០០០ | ១៩.២៨០.០០០ |
| ៥ | កំពង់ផែស្វយ័តភ្នំពេញ | សេវាកម្មកំពង់ផែ | ៤.១៣៦.៨៧៣ | ២១.១៨០.៧៨៩.៧៦០ | ៥.២៩៥.១៩៧ |
| ៦ | ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី | អភិវឌ្ឍតំបន់ សេដ្ឋកិច្ចពិសេស | ២៥.៥៧៥.០០០ | ៧៣.១៤៤.៥០០.០០០ | ១៨.២៨៦.១២៥ |
| ៧ | កំពង់ផែស្វយ័តក្រុងព្រះសីហនុ | សេវាកម្មកំពង់ផែ | ២១.៤៤២.៩៩២ | ១០៨.០៧២៦៧៩.៦៨០ | ២៧.០១៨.១៧០ |
| ៨ | ធនាគារ អេស៊ីលីដា ភីអិលស៊ី | ហិរញ្ញវត្ថុ | ៤.៣៤៤.៨៦៥ | ៧០.៣៨៦.៨១៣.០០០ | ១៧.៥៩៦.៧០៣ |
| ៩ | ផេសថិក(ខេមបូឌា) ម.ក | ថាមពល | ៣.៩៤៥.០០០ | ១២.៣០៨.៤០០.០០០ | ២.៩៩៨.២០០ |
| **ចំនួនសាច់ប្រាក់ដែលប្រមូលបានពីការបោះផ្សាយ** | | | | ៤៧៥.៥១៥.១៨៥.៣៨០ | ១១៨.៧៩៩.៨៩៦ |




ទិន្នន័យវិនិយោគចូលរួមក្នុងទីផ្សារមូលបត្រគិតត្រឹមឆ្នាំ២០២១




ទិន្នន័យទំហំជួញដូរមូលបត្រកម្មសិទ្ធិគិតត្រឹមឆ្នាំ២០២១




**ទំហំមូលធនីយកម្មទីផ្សារមូលបត្រកម្មសិទ្ធិគិតត្រឹមឆ្នាំ២០២១**

គិតត្រឹមឆ្នាំ២០២១ **ន.ម.ក.** បានផ្តល់ការអនុញ្ញាតដល់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្របំណុលចំនួន ៧ និងបានប្រមូលសាច់ប្រាក់ពីទីផ្សារប្រមាណជា ១៦៣ លានដុល្លារអាមេរិក។

| ល.រ | ឈ្មោះក្រុមហ៊ុន | អត្រាគូប៉ុង (ប្រចាំឆ្នាំ) | កាលបរិច្ឆេទចុះបញ្ជី | កាលប្រតិទាន | កាលប្រតិទាន (ឆ្នាំ) | ចំនួនបោះផ្សាយមូលបត្របំណុល (ឯកតា) | សាច់ប្រាក់ទទួលបានពីការបោះផ្សាយ (ដុល្លារ) |
|---|---|---|---|---|---|---|---|
| ១ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត | ៨,៥០% | ០៥ ធ្នូ ២០១៨ | ១៤ វិច្ឆិកា ២០២១ | ៣ | ១.២០០.០០០ | ៣០.០០០.០០០ |
| ២ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអិលអូអិលស៊ី (ខេមបូឌា)ភីអិលស៊ី | ៨,០០% | ១៦ ឧសភា ២០១៩ | ២៦ មេសា ២០២២ | ៣ | ៥៣៦.០០០ | ១៣.៤០០.០០០ |
| ៣ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី | ៩,០០% | ១០ ឧសភា ២០១៩ | ២៦ មេសា ២០២២ | ៣ | ២៦៤.០០០០ | ៦.៦០០.០០០ |
| ៤ | ធនាគារ អេប៊ីអេ | ៧,៧៥% | ២៣ សីហា ២០១៩ | ១៤ សីហា ២០២២ | ៣ | ៨៤៨.២១០ | ២១.២០៥.២៥០ |
| ៥ | ធនាគារភ្នំពេញពាណិជ្ជ" ភីភីស៊ីប៊ែង "ម.ក | ៦,៥០% | ២១ មេសា ២០២០ | ១០ មេសា ២០២៣ | ៣ | ៤០០.០០០ | ១០.០០០.០០០ |
| ៦ | ធនាគារភ្នំពេញពាណិជ្ជ" ភីភីស៊ីប៊ែង "ម.ក | ៦,៥០% | ១៩ តុលា ២០២០ | ២២ កញ្ញា ២០២៣ | ៣ | ៤០០.០០០ | ១០.០០០.០០០ |
| ៧ | អ អិម អេ (ខេមបូឌា) ម.ក | ៥,៥០% | ៣០ មេសា ២០២០ | ០៩ មេសា ២០២៥ | ៥ | ៨០០.០០០ | ២០.០០០.០០០ |
| ៨ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ម.ក | ៧,៥០% | ០៥ ឧសភា ២០២០ | ២៣ មេសា ២០២៣ | ៣ | ១.២៧២.០០០ | ៣១.៨០០.០០០ |
| ៩ | តែល កូថេក | ៤,៥០% | ០៩ កញ្ញា ២០២១ | ២៥ សីហា ២០២៦ | ៥ | ៨០០.០០០ | ២០.០០០.០០០ |
| **សាច់ប្រាក់សរុបទទួលបានពីការបោះផ្សាយ** | | | | | | | **១៦៣.០០៥.២៥០** |

**ទិន្នន័យក្រុមហ៊ុនចុះបញ្ជីលក់មូលបត្របំណុល**

គិតត្រឹមឆ្នាំ ២០២១ **ន.ម.ក.** បានផ្តល់ការអនុញ្ញាតលើផលិតផលឧបករណ៍និស្សន្ទ និងដាក់ឱ្យជួញដូរផលិតផល រួមមាន កិច្ចសន្យាលើតម្លៃមូលបត្រកម្មសិទ្ធិ កិច្ចសន្យាលើតម្លៃសន្ទស្សន៍

កិច្ចសន្យាលើគម្លាតថ្លៃប្រេងឆៅ កិច្ចសន្យាលើគម្លាតថ្លៃរូបិយបណ្ណបរទេស កិច្ចសន្យាលើគម្លាតថ្លៃលោហធាតុមានតម្លៃ កិច្ចសន្យាលើគម្លាតថ្លៃខុម្ម៉ូឌីធី និងផលិតផលផ្សេងទៀត ដែលមានទំហំជួញដូរសរុបចំនួន ៩៧៤.២០២,៥២ ឡូត (lots) ដែលគិតជាតម្លៃជួញដូរប្រហាក់ប្រហែលនឹង ១.៣៤៨ លានដុល្លារអាមេរិក និងមានវិនិយោគិនចំនួន ៦.៨៨៣។



ទិន្នន័យទំហំជួញដូរឧបករណ៍និស្សន្ទគិតជាឡូត



ទិន្នន័យទំហំជួញដូរឧបករណ៍និស្សន្ទគិតជាទឹកប្រាក់

| ល.រ | ប្រភេទឧបករណ៍និស្សន្ទ | ចំនួនឧបករណ៍និស្សន្ទគិតត្រឹមឆ្នាំ២០២១ |
|---|---|---|
| ១ | កិច្ចសន្យាលើគម្លាតថ្លៃរូបិយបណ្ណ | **១១៦** |
| ២ | កិច្ចសន្យាលើគម្លាតថ្លៃលោហធាតុមានតម្លៃ | **១១** |
| ៣ | កិច្ចសន្យាលើគម្លាតថ្លៃប្រេងឆៅ | **៨** |
| ៤ | កិច្ចសន្យាលើគម្លាតថ្លៃសន្ទស្សន៍ | **៣៧** |
| ៥ | កិច្ចសន្យាលើគម្លាតថ្លៃមូលបត្រកម្មសិទ្ធិ | **១៦** |
| ៦ | កិច្ចសន្យាលើគម្លាតថ្លៃខុម៉ូឌីធី | **៦** |
| **សរុប** | | **១៩៤** |

ប្រភេទ និងចំនួនឧបករណ៍និស្សន្ទត្រូវបានអនុញ្ញាតឱ្យជួញដូរ

# ៣. ការវាយតម្លៃតម្រូវការអភិវឌ្ឍស្ថាប័ន៖ បញ្ហាប្រឈម និងដំណោះស្រាយ

## ៣.១. ការវិភាគ និងវាយតម្លៃស្ថានភាពបច្ចុប្បន្ន (SWOT Analysis)

### ៣.១.១. ភាពខ្លាំង

- ស្ថាប័នកើតឡើងដោយច្បាប់
- អភិបាលកិច្ចល្អ តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធត្រូវបានកំណត់យ៉ាងច្បាស់លាស់
- ថ្នាក់ដឹកនាំមានសមត្ថភាពខ្ពស់ និងមានឆន្ទៈមោះមុត និងមានចក្ខុវិស័យវែងឆ្ងាយ
- ភាពចាស់ទុំ និងបទពិសោធន៍ច្រើនក្នុងការដឹកនាំនៅក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ
- មន្ត្រីជំនាញមានឆន្ទៈខ្ពស់ក្នុងការអនុវត្តការងារ
- ការអនុវត្តតួនាទីស្ថាប័នមួយចំនួន តាមបច្ចេកវិទ្យាហិរញ្ញវត្ថុ ដែលជំរុញឱ្យយន្តការបំពេញការងារមានប្រសិទ្ធភាព និងប្រព្រឹត្តទៅដោយរលូន

### ៣.១.២. ភាពខ្សោយ

- ភាពមិនទាន់ប្រទាក់ក្រឡាគ្នាល្អនៅក្នុងការអនុវត្តការងារ ដើម្បីសម្រេចគោលដៅរួម
- ចំនួនមន្ត្រីបំពេញការងាររួមទាំងសមត្ថភាពជំនាញទន់ និងរឹងរបស់មន្ត្រីជំនាញនៅមានកម្រិត ដែលមិនទាន់អាចឆ្លើយតបទៅនឹងទំហំការងារជាក់ស្តែងដែលកំពុងកើនឡើងជាលំដាប់
- លទ្ធភាពក្នុងការផ្តល់ការលើកទឹកចិត្តដល់មន្ត្រីនៅមានកម្រិត
- ការអភិវឌ្ឍបច្ចេកវិទ្យាសម្រាប់អនុវត្តមុខងារស្ថាប័ន និងលើកកម្ពស់ប្រសិទ្ធភាពក្នុងការបំពេញការងារជាប្រចាំនៅមានកម្រិត

### ៣.១.៣. ភាពប្រឈម

- ការសម្របខ្លួនទៅនឹងប្រក្រតីភាពថ្មី (New Normal) មិនទាន់បានពេញលេញ
- ចល័តភាពមន្ត្រីមានកម្រិតខ្ពស់ ដោយសារស្ថាប័នដទៃទៀតផ្តល់ប្រាក់ឧបត្ថម្ភ ឬប្រាក់លើកទឹកចិត្តខ្ពស់ជាង
- ការវិវត្តថ្មីនៃឧបករណ៍ហិរញ្ញវត្ថុ និងបច្ចេកវិទ្យាហិរញ្ញវត្ថុនៅក្នុងវិស័យមូលបត្រ ដែលទាមទារឱ្យមានការអភិវឌ្ឍបន្ថែមនូវសមត្ថភាព ហេដ្ឋារចនាសម្ព័ន្ធ និងក្របខណ្ឌគតិយុត្តដើម្បីគ្រប់គ្រង
- សេចក្តីត្រូវការក្នុងការលើកកម្ពស់បន្ថែមទៀតលើការយល់ដឹងអំពីសារៈសំខាន់ និងការវិនិយោគក្នុងវិស័យមូលបត្រ រួមទាំងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ
- សេចក្តីត្រូវការក្នុងការជំរុញបន្ថែមទៀតឱ្យមានក្រុមហ៊ុនបោះផ្សាយ និងវិនិយោគិនឱ្យកាន់តែច្រើននៅក្នុងទីផ្សារ

### ៣.១.៤. កាលានុវត្តភាព

- សន្តិភាព ស្ថិរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ចអាចឱ្យស្ថាប័នអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន
- ការរីកចម្រើននៃវិស័យមូលបត្រ ជំរុញឱ្យមានការពង្រីកស្ថាប័នកាន់តែធំ
- ការរីកចម្រើននៃបច្ចេកវិទ្យាព័ត៌មាន ជំរុញឱ្យមានការបំប្លែងខ្លួនទៅជាស្ថាប័នបែបឌីជីថលក្នុងបរិបទសេដ្ឋកិច្ចឌីជីថល និងជំរុញឱ្យមានការកសាងសមត្ថភាពធនធានមនុស្ស
- ការទទួលបាននូវឧបករណ៍ហិរញ្ញវត្ថុ និងបច្ចេកវិទ្យាហិរញ្ញវត្ថុថ្មីៗ ដើម្បីអភិវឌ្ឍស្ថាប័ន និងវិស័យមូលបត្រ
- ការធ្វើសមាហរណកម្មអាស៊ាន និងការរីកចម្រើននៃវិស័យមូលបត្រ បានជំរុញឱ្យបង្កើត និងពង្រឹងកិច្ចសហប្រតិបត្តិការ នៅក្នុងថ្នាក់ជាតិ ថ្នាក់តំបន់ និងលើឆាកអន្តរជាតិ

## ៣.២. ឧបសគ្គ បញ្ហាប្រឈម ភាពខ្វះចន្លោះ និងដំណោះស្រាយ

តាមរយៈការវិភាគ និងវាយតម្លៃស្ថានភាពបច្ចុប្បន្នដូចបានបង្ហាញខាងលើ **គ.ម.ក.** ដែលជាស្ថាប័នគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រឈមនឹងឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះមួយចំនួនដូចជា÷

- ភាពមិនទាន់ប្រទាក់ក្រឡាគ្នាល្អនៅក្នុងការអនុវត្តការងារ ដើម្បីសម្រេចគោលដៅរួម
- ភាពត្រួតស៊ីគ្នានៃការអនុវត្តមុខងារ និងតួនាទីទៅលើផ្នែកមួយចំនួន
- ចំនួនមន្ត្រីបំពេញការងាររួមទាំងសមត្ថភាពជំនាញទន់ និងរឹងរបស់មន្ត្រីជំនាញនៅមានកម្រិត មិនទាន់អាចឆ្លើយតបទៅនឹងទំហំការងារជាក់ស្តែងដែលកំពុងកើនឡើងជាលំដាប់
- ភាពខ្វះចន្លោះនៃការគ្រប់គ្រងធនធានមនុស្ស រួមបញ្ចូលទាំងលទ្ធភាពក្នុងការផ្តល់ការលើកទឹកចិត្តមន្ត្រីនៅមានកម្រិត
- ការអភិវឌ្ឍបច្ចេកវិទ្យាសម្រាប់អនុវត្តមុខងារស្ថាប័ន និងលើកកម្ពស់ប្រសិទ្ធភាពក្នុងការបំពេញការងារជាប្រចាំនៅមានកម្រិតនៅឡើយ
- ការសម្របខ្លួនទៅនឹងប្រក្រតីភាពថ្មី (New Normal) មិនទាន់បានពេញលេញ
- លំហូរចាកចេញរបស់មន្ត្រីមានកម្រិតខ្ពស់ ដោយសារស្ថាប័នដទៃទៀតផ្តល់ប្រាក់ឧបត្ថម្ភ ឬប្រាក់លើកទឹកចិត្តខ្ពស់ជាង
- ការវិវត្តថ្មីនៃឧបករណ៍ហិរញ្ញវត្ថុ និងបច្ចេកវិទ្យាហិរញ្ញវត្ថុនៅក្នុងវិស័យមូលបត្រ ដែលទាមទារឱ្យមានការអភិវឌ្ឍបន្ថែមនូវសមត្ថភាព ហេដ្ឋារចនាសម្ព័ន្ធ និងក្របខណ្ឌគតិយុត្តដើម្បីគ្រប់គ្រង
- សេចក្តីត្រូវការក្នុងការលើកកម្ពស់បន្ថែមទៀតលើការយល់ដឹងអំពីសារៈសំខាន់ និងការវិនិយោគ

ក្នុងវិស័យមូលបត្រ រួមទាំងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ

- សេចក្តីត្រូវការក្នុងការជំរុញបន្ថែមទៀតឱ្យមានក្រុមហ៊ុនបោះផ្សាយ និងវិនិយោគិនឱ្យកាន់តែច្រើននៅក្នុងទីផ្សារ

ជាដំណោះស្រាយចំពោះឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះទាំងនេះ **ន.ម.ភ.** បានដាក់ចេញគោលនយោបាយអភិវឌ្ឍន៍អាទិភាពចំនួន ២ រួមមាន÷ **ផែនការសកម្មភាពជំរុញការអភិវឌ្ឍស្ថាប័ន** តាមរយៈការពង្រឹងអភិបាលកិច្ច, ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងការធ្វើបរិវត្តកម្មឌីជីថល, ការជំរុញការបោះផ្សាយលក់មូលបត្រ ការគ្រប់គ្រង និងការត្រួតពិនិត្យតួអង្គពាក់ព័ន្ធក្នុងវិស័យមូលបត្រ, និងការគាំពារវិនិយោគិនក្នុងវិស័យមូលបត្រ និង**ផែនការសកម្មភាពគាំទ្រការអភិវឌ្ឍស្ថាប័ន** តាមរយៈការពង្រឹងនិងពង្រីកកិច្ចការស្រាវជ្រាវ និងការរៀបចំបទប្បញ្ញត្តិចាំបាច់បន្ថែម ដើម្បីបន្តគាំទ្រការអភិវឌ្ឍវិស័យមូលបត្រ, ការពង្រឹង និងពង្រីកការបណ្តុះបណ្តាល ព្រមទាំងការងារផ្សព្វផ្សាយ និងកិច្ចសហប្រតិបត្តិការ។

## ៤. ចក្ខុវិស័យ គោលបំណង និងគោលដៅ

### ៤.១. ចក្ខុវិស័យ

**ន.ម.ក.** ជានិយ័តករគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យមូលបត្រប្រកបដោយវិជ្ជាជីវៈខ្ពស់ ប្រសិទ្ធភាព និងនិរន្តរភាព ដើម្បីធានាបានថាវិស័យមូលបត្រនៅកម្ពុជាមានការអភិវឌ្ឍប្រកបដោយនិរន្តរភាព ភាពធន់ និងបរិយាបន្ន និងមានទីផ្សារមួយដែលអភិវឌ្ឍស្របតាមឧត្តមានុវត្តអន្តរជាតិនិងដែលប្រកបដោយបូរណភាព (Market Integrity) ពេញលេញ សំដៅរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមជាតិទាំងមូល។

### ៤.២. គោលបំណង

ផែនការនេះ មានគោលបំណងផ្តល់នូវក្របខណ្ឌរួមមួយដែលជាឯកសាររស់សម្រាប់ការអភិវឌ្ឍស្ថាប័ន **ន.ម.ក.** ដោយកំណត់ច្បាស់អំពីទិសដៅ គោលដៅ និងផែនការសកម្មភាពលម្អិត ដើម្បីពង្រឹងសមត្ថភាព និងបំពេញតួនាទីនិងភារកិច្ចខ្លួនប្រកបដោយផលិតភាព ប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់។

### ៤.៣. គោលដៅ

ផែនការនេះ មានគោលដៅពង្រឹងសមត្ថភាព មុខងារ និងតួនាទីរបស់ **ន.ម.ក.** តាមរយៈការអនុវត្តតាមផែនការសកម្មភាពជុំវិញ និងផែនការសកម្មភាពគាំទ្រការអភិវឌ្ឍស្ថាប័ន **ន.ម.ក.**។

## ៥. ផែនការសកម្មភាពអភិវឌ្ឍស្ថាប័ន

### ៥.១. គោលការណ៍នៃការរៀបចំ និងអនុវត្តសកម្មភាពការងារ

ដើម្បីធានានូវប្រសិទ្ធភាពនៃការដាក់ចេញផែនការអភិវឌ្ឍន៍ស្ថាប័ន **ន.ម.ភ.** បានរៀបចំសកម្មភាពការងារដោយអនុលោមទៅតាមគោលការណ៍ SMART ទាំង៥ ដូចខាងក្រោម÷

- ជាក់លាក់ (Specific)÷ សកម្មភាពការងារនីមួយៗដែលបានដាក់ចេញត្រូវមានភាពជាក់លាក់
- អាចវាស់វែងបាន (Measurable)÷ សកម្មភាពការងារនីមួយៗដែលបានដាក់ចេញត្រូវតែអាចកំណត់បានជាបរិមាណដើម្បីសម្គាល់វឌ្ឍនភាព
- អាចសម្រេចបាន (Achievable)÷ សកម្មភាពការងារនីមួយៗដែលបានដាក់ចេញត្រូវតែមានទំហំ ឬគោលដៅដែលអាចសម្រេចបាន
- ជាប់ទាក់ទង (Relevant)÷ សកម្មភាពការងារនីមួយៗដែលបានដាក់ចេញត្រូវតែមានការជាប់ទាក់ទងគោលបំណង និងគោលដៅនៃផែនការអភិវឌ្ឍស្ថាប័ននេះ
- មានពេលវេលាកំណត់ (Time bound)÷ សកម្មភាពការងារនីមួយៗដែលបានដាក់ចេញត្រូវតែមានការកំណត់ពេលវេលាជាក់លាក់សម្រាប់ការអនុវត្ត។

ការរៀបចំ និងអនុវត្តសកម្មភាពការងារដែលមានលម្អិតនៅក្នុងផែនការអភិវឌ្ឍន៍ស្ថាប័ន ៥ ឆ្នាំ (២០២១-២០២៥) នេះ គឺត្រូវបានធ្វើឡើងដោយគោរពទៅតាមគោលការណ៍ជាអភិក្រមធំៗ ចំនួន ២ របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ រួមមាន÷ ទី១ - រៀនផង ធ្វើផង ឬ ឆ្លងស្ទឹង ស្ទាបថ្ម និងទី២ - ទទួលយក (Adopt) បន្សាំ (Adapt) និងនវានុវត្តន៍បន្ថែម (Innovate further)។

### ៥.២. ក្របខណ្ឌយុទ្ធសាស្ត្រ

ការរៀបចំសកម្មភាពការងារក្នុងផែនការអភិវឌ្ឍន៍ស្ថាប័ននេះ ឈរលើសសរស្តម្ភធំៗ ចំនួន២ រួមមាន÷

- **ផែនការសកម្មភាពជំរុញការអភិវឌ្ឍស្ថាប័ន**÷ ផ្តោតជាសំខាន់លើសកម្មភាពដែលជំរុញការអភិវឌ្ឍ **ន.ម.ភ.** រួមមាន÷ ការពង្រឹងអភិបាលកិច្ច, ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងការធ្វើបរិវត្តកម្មឌីជីថល, ការជំរុញការបោះផ្សាយលក់មូលបត្រ ការគ្រប់គ្រង និងត្រួតពិនិត្យតួអង្គពាក់ព័ន្ធក្នុងវិស័យមូលបត្រ, ការគាំពារវិនិយោគិនក្នុងវិស័យមូលបត្រ។
- **ផែនការសកម្មភាពគាំទ្រការអភិវឌ្ឍស្ថាប័ន**÷ ផ្តោតជាសំខាន់លើសកម្មភាពដែលគាំទ្រការអភិវឌ្ឍ **ន.ម.ភ.** រួមមាន÷ ការពង្រឹង និងពង្រីកកិច្ចការស្រាវជ្រាវ និងការរៀបចំបទប្បញ្ញត្តិចាំបាច់

បន្ថែម ដើម្បីបន្តគាំទ្រការអភិវឌ្ឍវិស័យមូលបត្រ, ការពង្រឹង និងពង្រីកការបណ្តុះបណ្តាល ព្រមទាំងការងារផ្សព្វផ្សាយ និងកិច្ចសហប្រតិបត្តិការ។

## ៥.៣. សកម្មភាពការងារ

### ៥.៣.១. សកម្មភាពជុំវិញការអភិវឌ្ឍស្ថាប័ន

#### ៥.៣.១.១. ចង្កោមសកម្មភាពទី១÷ ការពង្រឹងអភិបាលកិច្ច

##### ក. ការពង្រឹងរចនាសម្ព័ន្ធស្ថាប័ន

**ន.ម.ក.** ត្រូវការបំពេញបន្ថែមនូវរចនាសម្ព័ន្ធស្ថាប័នឱ្យបានពេញលេញដើម្បីបំពេញមុខងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាពក្នុងការគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យមូលបត្រនៅកម្ពុជា។ មុខងារ និងរចនាសម្ព័ន្ធរបស់ **ន.ម.ក.** ត្រូវបានកំណត់នៅក្នុងច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជនដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧, អនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា, ប្រកាសពាក់ព័ន្ធនឹងការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទគណៈកម្មការមូលបត្រកម្ពុជាក្នុងឆ្នាំ២០០៩,ប្រកាសពាក់ព័ន្ធនឹងការបង្កើតការិយាល័យចំណុះឱ្យនាយកដ្ឋានពាក់ព័ន្ធនៃគណៈកម្មការមូលបត្រកម្ពុជាក្នុងឆ្នាំ២០១៧។

ដើម្បីបន្តពង្រឹងរចនាសម្ព័ន្ធស្ថាប័ន **ន.ម.ក.** បានដាក់ចេញនូវផែនការសកម្មភាពចម្បងដូចខាងក្រោម÷

- ចូលរួមរៀបចំបទប្បញ្ញត្តិកំណត់រចនាសម្ព័ន្ធនៃ **អ.ស.ហ.** និងរចនាសម្ព័ន្ធនៃ **ន.ម.ក.** (ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារដែលត្រូវបានប្រកាសដាក់ឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ និងអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដែលកំណត់រចនាសម្ព័ន្ធរបស់ **ន.ម.ក.**)
- ចូលរួមរៀបចំ និងចាត់ចែងរៀបចំបទប្បញ្ញត្តិពាក់ព័ន្ធនឹងក្របខណ្ឌមន្ត្រី **ន.ម.ក.** ការតែងតាំងថ្នាក់ដឹកនាំ និងមន្ត្រី ព្រមទាំងការបែងចែកភារកិច្ច (ព្រះរាជក្រឹត្យលេខ នស/រកម/០២២១/១៨៤ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីការតែងតាំងមុខតំណែង និងផ្តល់ឋានៈដល់មន្ត្រីរាជការនៃ **អ.ស.ហ.**, ព្រះរាជក្រឹត្យលេខ នស/រកត/០៨២១/៥៦៥ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ ២០២១ ស្តីពីការតែងតាំងមុខតំណែង និងផ្តល់ឋានៈដល់មន្ត្រីរាជការនៃ **អ.ស.ហ.**, សេចក្តី

សម្រេចលេខ ១៩៣/២១ ន.ម.ក./ស.ស.រ. ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីការបែងចែកភារកិច្ចរបស់អគ្គនាយករង **ន.ម.ក.**, ប្រកាសលេខ ០១០ អ.ស.ហ.ប្រក ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២១ ស្តីពីលក្ខន្តិកៈនៃមន្ត្រីលក្ខន្តិកៈរបស់ **អ.ស.ហ.**, ប្រកាសលេខ ០១៧ អសហ.ប្រក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការតែងតាំង និងផ្ទេរភារកិច្ចមន្ត្រីនៃ **ន.ម.ក.** នៃ **អ.ស.ហ.**, សេចក្តីសម្រេចលេខ ២៣២/២១ ន.ម.ក./ស.ស.រ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការប្រគល់ភារកិច្ចជូនអនុប្រធាននាយកដ្ឋាន អនុប្រធានការិយាល័យ និងការចាត់តាំងមន្ត្រីនៃនាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ, អនុក្រឹត្យលេខ ១១៣ អនក្រ.តត ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២២ ស្តីពីការតែងតាំងមន្ត្រីរាជការនៃ **អ.ស.ហ.**, ប្រកាសលេខ ០១៥ អ.ស.ហ. ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២ ស្តីពីការធ្វើសមាហរណកម្មមន្ត្រីលក្ខន្តិកៈនៃ **ន.ម.ក.** ជាមន្ត្រីលក្ខន្តិកៈរបស់ **អ.ស.ហ.** និងការទទួលស្គាល់មន្ត្រីលក្ខន្តិកៈរបស់ **អ.ស.ហ.**)។

### ខ. ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស

គិតត្រឹមបំណាច់ឆ្នាំ២០២០ **ន.ម.ក.** មានថ្នាក់ដឹកនាំ និងមន្ត្រីសរុបចំនួន ១៧៦ រូប ដែលក្នុងនោះរួមមាន មន្ត្រីរាជការក្របខណ្ឌមុខងារសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចំនួន ៦៣ រូប មន្ត្រីលក្ខន្តិកៈ ចំនួន ៩៦ រូប និងមន្ត្រីជាប់កិច្ចសន្យាចំនួន ១៧ រូប។

បន្ទាប់ពីបានបង្កើត **អ.ស.ហ.** **ន.ម.ក.** បានទទួលការអនុញ្ញាតឱ្យចែករំលែកមន្ត្រីជំនាញរបស់ខ្លួនទៅបំពេញការងារនៅនិយ័តករពាក់ព័ន្ធនៃ **អ.ស.ហ.** និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ដើម្បីធានានូវនិរន្តរភាព និងប្រសិទ្ធភាពការងារនៅឆ្នាំ២០២២ **ន.ម.ក.** បានទទួលការអនុញ្ញាតឱ្យធ្វើការជ្រើសរើសមន្ត្រីជំនួស ក្នុងចំនួនសរុប ៤៤ រូប សម្រាប់បង្គ្រប់ចំនួនមន្ត្រីសរុប ១៧៦ រូប។ ចំនួនមន្ត្រីដែលមានទាំងនេះនៅមិនទាន់អាចឆ្លើយតបបានទាំងស្រុងទៅនឹងតួនាទី និងភារកិច្ច តាមរចនាសម្ព័ន្ធរបស់ **ន.ម.ក.** នៅឡើយ។ ដូចនេះ ចាប់ពីឆ្នាំ២០២៤ **ន.ម.ក.** បានដាក់ចេញនូវផែនការជ្រើសរើសមន្ត្រីបន្ថែមតាមស្ថានភាពនៃទំហំការងារជាក់ស្តែង និងភាពរីកចម្រើននៃវិស័យមូលបត្រ។

ជាមួយនឹងការបំពេញបន្ថែមនូវចំនួនមន្ត្រី ការអភិវឌ្ឍធនធានមនុស្សជាសកម្មភាពអាទិភាពដែល **ន.ម.ក.** តែងតែយកចិត្តទុកដាក់ខ្ពស់ តាមរយៈការដាក់ចេញនូវផែនការសកម្មភាពចម្បងដូចខាងក្រោម÷

- រៀបចំ និងដាក់ឱ្យប្រើប្រាស់សៀវភៅមគ្គុទ្ទេសក៍អភិវឌ្ឍធនធានមនុស្ស
- រៀបចំបណ្តុះបណ្តាលកសាងសមត្ថភាពមន្ត្រីទាំងជំនាញទន់ និងជំនាញរឹង
- អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរបស់ **ន.ម.ក.** តាមប្រព័ន្ធបច្ចេកវិទ្យា និងប្រមូលផ្តុំទិន្នន័យ ដូចជា ប្រព័ន្ធគ្រប់គ្រងវត្តមាន (ឧបករណ៍ស្កេនមុខ) និងប្រព័ន្ធគ្រប់គ្រងព័ត៌មានមន្ត្រីជាដើម។

### គ. ការពង្រឹងប្រព័ន្ធគ្រប់គ្រងគណនេយ្យ និងហិរញ្ញវត្ថុ

ក្នុងទិសដៅពង្រឹងប្រព័ន្ធគ្រប់គ្រងគណនេយ្យ និងហិរញ្ញវត្ថុ **ន.ម.ភ.** បានដាក់ចេញនូវផែនការសកម្មភាពចម្បងដូចខាងក្រោម÷

- រៀបចំគម្រោងថវិកាសម្រាប់កិច្ចដំណើរការរបស់ **ន.ម.ភ.** និងតាមដានការអនុវត្តថវិកា
- រៀបចំនីតិវិធីក្នុងការរៀបចំអនុវត្តថវិកា និងគ្រប់គ្រងហិរញ្ញវត្ថុរបស់ **ន.ម.ភ.** ឱ្យស្របតាមហិរញ្ញវត្ថុសាធារណៈ
- អភិវឌ្ឍប្រព័ន្ធប្រើប្រាស់សម្រាប់ការអនុវត្តថវិកា និងគ្រប់គ្រងហិរញ្ញវត្ថុរបស់ **ន.ម.ភ.**
- គ្រប់គ្រងរាល់ចំណូល-ចំណាយរបស់ **ន.ម.ភ.** និងគ្រប់គ្រងបញ្ជិកា និងបញ្ជីស្នាមគណនេយ្យទាំងអស់របស់ **ន.ម.ភ.** ព្រមទាំងរៀបចំរបាយការណ៍ចំណូល-ចំណាយរបស់ **ន.ម.ភ.** ជាប្រចាំខែ
- រៀបចំផែនការពិនិត្យ និងតាមដានការអនុវត្តនីតិវិធីលទ្ធកម្មថវិកាជាតិរបស់ **ន.ម.ភ.** ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាព និងទាន់ពេលវេលា
- រៀបចំតារាងកើនឡើង-ថយចុះនៃទ្រព្យសម្បត្តិរដ្ឋរបស់ **ន.ម.ភ.**
- រៀបចំប្រកាសស្ដីពីការកំណត់ប្រភព និងការគ្រប់គ្រងធនធានហិរញ្ញវត្ថុរបស់ **ន.ម.ភ.**

### ឃ. ការលើកកម្ពស់ប្រសិទ្ធភាពប្រតិបត្តិការការងារ និងបច្ចេកវិទ្យាព័ត៌មាន

ក្នុងទិសដៅធានាឱ្យបាននូវប្រសិទ្ធភាពនៃការអនុវត្តការងារ **ន.ម.ភ.** បានដាក់ចេញផែនការសកម្មភាពចម្បងដូចខាងក្រោម÷

- ចូលរួមរៀបចំបទប្បញ្ញត្តិកំណត់ប្រាក់បៀវត្សសម្រាប់មន្ត្រីលក្ខន្តិកៈ និងរៀបចំគោលការណ៍លើកទឹកចិត្តមន្ត្រី **ន.ម.ភ.** ពាក់ព័ន្ធនឹងការតម្លើងឋានៈ និងឋានន្តរស័ក្តិ និងការផ្ដល់ប្រាក់ឧបត្ថម្ភ ប្រាក់រង្វាន់ លិខិត ឬបណ្ណសរសើរ មេដាយការងារ និងអត្ថប្រយោជន៍ផ្សេងៗ (ប្រកាសលេខ ០២២ អ.ស.ហ. ប្រ.ក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ស្ដីពីការកំណត់ប្រាក់បៀវត្សសម្រាប់មន្ត្រីលក្ខន្តិកៈ និងមន្ត្រីជាប់កិច្ចសន្យារបស់ **អ.ស.ហ.**, ប្រកាសលេខ ០០៨ អ.ស.ហ ប្រ.ក ស្ដីពីការកំណត់ប្រាក់ឧបត្ថម្ភជីវភាពសម្រាប់ថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិករបស់ **អ.ស.ហ.** ចុះថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ២០២២)
- ពង្រឹងការអនុវត្ត និងបន្តរៀបចំនីតិវិធីប្រតិបត្តិស្តង់ដាសម្រាប់ការបំពេញការងារជាប្រចាំរបស់នាយកដ្ឋាននីមួយៗចំណុះ **ន.ម.ភ.**
- អភិវឌ្ឍ និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងឯកសារ និងប្រព័ន្ធត្រួតពិនិត្យវឌ្ឍនភាពការងាររបស់មន្ត្រី

- រៀបចំ និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបើកប្រាក់បៀវត្ស ប្រាក់បេសកកម្ម និងប្រាក់ឧបត្ថម្ភតាមប្រព័ន្ធធនាគារ
- បង្កើតបណ្តាញផ្សព្វផ្សាយផ្លូវការរបស់ **ន.ម.ក.** រួមមាន÷ គេហទំព័រ បណ្តាញទំនាក់ទំនងសង្គមហ្វេសបុក បណ្តាញយូធូប កម្មវិធីទូរសព្ទដៃ (SERC App) និងបណ្តាញតេឡេក្រាម
- រៀបចំ និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធស្នើសុំលេខអត្តសញ្ញាណវិនិយោគិនតាមប្រព័ន្ធអនឡាញ
- រៀបចំ និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងបន្ទប់ប្រជុំតាមប្រព័ន្ធអនឡាញ
- ពង្រឹង និងពង្រីកសមត្ថភាពមជ្ឈមណ្ឌលទិន្នន័យ រួមទាំងស៊ិរភាពនៃហេដ្ឋារចនាសម្ព័ន្ធ និងធនធានបច្ចេកវិទ្យាព័ត៌មាន
- អភិវឌ្ឍ និងដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធបច្ចេកវិទ្យាសំខាន់ៗសម្រាប់ការបង្ហាញព័ត៌មានសាជីវកម្ម ប្រព័ន្ធគ្រប់គ្រង និងវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបោះផ្សាយមុន និងក្រោយ IPO, ការត្រួតពិនិត្យប្រតិបត្តិការ និងអាជីវកម្មជួញដូរឧបករណ៍និស្សន្ទ, ការគ្រប់គ្រងមូលដ្ឋានទិន្នន័យ (Database) របស់ក្រុមហ៊ុនអន្តរការីមូលបត្រ, ការចុះឈ្មោះ និងបង់ថ្លៃចូលរួមវគ្គបណ្តុះបណ្តាលតាមប្រព័ន្ធឌីជីថល, ថ្នាលបណ្តុះបណ្តាល និងការប្រឡងតាមប្រព័ន្ធឌីជីថល និងការទាញយកមូលដ្ឋានទិន្នន័យក្នុងវិស័យមូលបត្រ។

**ង. ការលើកកម្ពស់បរិស្ថាន និងលក្ខខណ្ឌការងារ**

ក្នុងទិសដៅបង្កើនប្រសិទ្ធភាព និងលើកទឹកចិត្តដល់ការបំពេញការងាររបស់ថ្នាក់ដឹកនាំ និងមន្ត្រី **ន.ម.ក.** បានរៀបចំ និងមានផែនការសកម្មភាពចម្បងដូចខាងក្រោម÷

- សាងសង់អគារ **ន.ម.ក.** ដែលមានទីធ្លាធំទូលាយ និងមានផាសុកភាពសម្រាប់ការបំពេញការងារ (ក្រោយមកបានក្លាយជាអគារ **អ.ស.ហ.**) និងបានចូលរួមពិនិត្យរៀបចំអគារ **អ.ស.ហ.** បន្ថែមលើទីតាំងដីដែល **ន.ម.ក.** បានទទួលការអនុញ្ញាតទិញយកបន្ថែមក្នុងឆ្នាំ២០២១
- រៀបចំ និងចូលរួមពង្រីកចំណតយានជំនិះសម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រី **ន.ម.ក.**
- បង្កើតឱ្យមានទីកន្លែងសម្រាប់បរិភោគអាហារថ្ងៃត្រង់ និងបានធ្វើបដិភាគចំនួន ៨.០០០រៀល លើអាហារថ្ងៃត្រង់សម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រី **ន.ម.ក.**
- រៀបចំបំពាក់ឧបករណ៍បច្ចេកវិទ្យាព័ត៌មានសម្រាប់បំពេញការងារដល់ថ្នាក់ដឹកនាំ និងមន្ត្រីដូចជា កុំព្យូទ័រ បណ្តាញតភ្ជាប់ បណ្តាញអ៊ិនធឺណិតដែលមានល្បឿនលឿន ប្រព័ន្ធ ZOOM ប្រព័ន្ធសម្លេង កាមេរ៉ាថតរូបឌីជីថល ទូរទស្សន៍ ឧគ្ឃោសនសព្ទ ឧបករណ៍ថតសម្លេង និង LCD Projector ជាដើម។

### ៥.៣.១.២. ចង្កោមសកម្មភាពទី២÷ ការជំរុញការបោះផ្សាយលក់មូលបត្រ ការគ្រប់គ្រង និង ការត្រួតពិនិត្យតួអង្គពាក់ព័ន្ធក្នុងវិស័យមូលបត្រ

#### ក. ការជំរុញការបោះផ្សាយលក់មូលបត្រ

ក្នុងទិសដៅជំរុញការបោះផ្សាយលក់មូលបត្រ **ន.ម.ក.** បានដាក់ចេញនូវផែនការសកម្មភាពចម្បងដូចខាងក្រោម÷

- រៀបចំអនុក្រឹត្យស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ (អនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១, អនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៩, អនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២)
- រៀបចំកម្មវិធីឧត្តមភាពលើកទី២ ក្នុងគោលដៅជួយជំរុញដល់សហគ្រាសធុនតូច និងមធ្យមអាចមានលទ្ធភាពទទួលបានហិរញ្ញប្បទានបន្ថែមតាមរយៈទីផ្សារមូលបត្រ
- រៀបចំ និងដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការបោះផ្សាយលក់សញ្ញាបណ្ណបៃតង សង្គម និងនិរន្តរភាព
- រៀបចំ និងដាក់ចេញនូវប្រកាសពាក់ព័ន្ធនឹងការបោះផ្សាយមូលបត្រលក់ឯកតាបរធនវិនិយោគអចលនវត្ថុនៃគម្រោងវិនិយោគរួម, ការបោះផ្សាយលក់មូលបត្រសម្រាប់ក្រុមហ៊ុនបរទេស, ការបោះផ្សាយលក់មូលនិធិដែលអាចជួញដូរបាន, ការបោះផ្សាយលក់ឯកតាមូលនិធិនៃគម្រោងវិនិយោគរួម, ការបោះផ្សាយលក់កិច្ចសន្យាអុបសិន និងកិច្ចសន្យាអនាគត, ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈសម្រាប់ក្រុមហ៊ុនហូលឌីង និងការបោះផ្សាយលក់ទ្រព្យឌីជីថល។

#### ខ. ការគ្រប់គ្រង និងការត្រួតពិនិត្យក្រុមហ៊ុនបោះផ្សាយ

ក្នុងគោលដៅធានាឱ្យបាននូវទំនុកចិត្តលើក្រុមហ៊ុនបោះផ្សាយ **ន.ម.ក.** បានដាក់ចេញនូវផែនការសកម្មភាពចម្បងដូចខាងក្រោម÷

- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តអភិបាលកិច្ចសាជីវកម្ម និងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបោះផ្សាយ
- ត្រួតពិនិត្យការបង្ហាញព័ត៌មានសាជីវកម្មរបស់ក្រុមហ៊ុនបោះផ្សាយ
- រៀបចំគោលការណ៍ណែនាំស្តីពីបរិស្ថាន សង្គម និងអភិបាលកិច្ច (Environment Social and Governance-ESG)
- រៀបចំ និងដាក់ចេញនូវយន្តការនៃការជំរុញការអនុវត្តរបស់វិនិយោគិនស្ថាប័នដើម្បីគាំទ្រ ESG។

### គ. ការគ្រប់គ្រង ការត្រួតពិនិត្យ និងការតាមដានប្រតិបត្តិករនៅក្នុងទីផ្សារមូលបត្រ

ដើម្បីរក្សាឱ្យបាននូវតម្លាភាព និងសណ្តាប់ធ្នាប់ទីផ្សារ **ន.ម.ក.** បានដាក់ចេញនូវផែនការសកម្មភាពចម្បងដូចខាងក្រោម÷

- ត្រួតពិនិត្យ តាមដានការអនុវត្តកាតព្វកិច្ច និងចុះត្រួតពិនិត្យដល់ទីកន្លែង ឬតាមប្រព័ន្ធអនឡាញលើប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- រៀបចំ និងដាក់ឱ្យអនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធនឹងការគ្រប់គ្រង និងការត្រួតពិនិត្យប្រតិបត្តិកររក្សាទុកមូលបត្រ ប្រតិបត្តិការជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិការទីផ្សារមូលបត្រ
- រៀបចំ និងដាក់ឱ្យអនុវត្តប្រកាសពាក់ព័ន្ធនឹងការផ្តល់ការអនុញ្ញាតធ្វើជាប្រតិបត្តិករទីផ្សារមូល-បត្រអនាគត និងការផ្តល់ការអនុញ្ញាតធ្វើជាប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់ទីផ្សារមូលបត្រអនាគត ឬ/និងប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់ឧបករណ៍និស្សន្ទ
- រៀបចំ និងដាក់ឱ្យអនុវត្តគោលការណ៍ណែនាំសម្រាប់ការចុះត្រួតពិនិត្យដល់ទីកន្លែងលើប្រតិ-បត្តិករ។

### ឃ. ការគ្រប់គ្រង និងការត្រួតពិនិត្យអន្តរការីមូលបត្រ

ដើម្បីធានាបាននូវការគ្រប់គ្រង និងត្រួតពិនិត្យអន្តរការីមូលបត្រ ប្រកបដោយប្រសិទ្ធភាព **ន.ម.ក.** បានដាក់ចេញនូវផែនការសកម្មភាពចម្បងដូចខាងក្រោម÷

- ពិនិត្យពាក្យស្នើសុំ និងផ្តល់អាជ្ញាបណ្ណ/ការអនុញ្ញាត អាជ្ញាបណ្ណ/ការអនុញ្ញាតបន្ត និងការទទួលស្គាល់គុណវុឌ្ឍិដល់ក្រុមហ៊ុនអន្តរការីមូលបត្រ និងបុគ្គលពាក់ព័ន្ធ
- ត្រួតពិនិត្យ និងតាមដានសកម្មភាពរបស់ក្រុមហ៊ុនអន្តរការីមូលបត្រក្នុងការគោរពតាមលក្ខខណ្ឌអាជ្ញាបណ្ណ/ការអនុញ្ញាត និងលក្ខខណ្ឌហិរញ្ញវត្ថុ
- ត្រួតពិនិត្យជាក់ស្តែងដល់ទីកន្លែងនូវប្រតិបត្តិការរបស់ក្រុមហ៊ុនអន្តរការីមូលបត្រ។

### ង. ការគ្រប់គ្រង និងការត្រួតពិនិត្យក្រុមហ៊ុនផ្តល់សេវាសវនកម្ម ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ការិយាល័យមេធាវី ភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល និងភ្នាក់ងារវាយតម្លៃលទ្ធ-ភាពសង

ដើម្បីធានាបាននូវការគ្រប់គ្រង និងការត្រួតពិនិត្យក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យមូលបត្រ ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ការិយាល័យមេធាវី ភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល និងភ្នាក់ងារវាយ-តម្លៃលទ្ធភាពសង ប្រកបដោយប្រសិទ្ធភាព **ន.ម.ក.** បាន និងបន្តផ្តល់ការទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវា

សវនកម្ម ក្រុមហ៊ុនបកប្រែ ការិយាល័យមេធាវី ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល និងភ្នាក់ងារវាយតម្លៃលទ្ធភាពសង រួមទាំងពិនិត្យលើរបាយការណ៍ធុរកិច្ច របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងកាតព្វកិច្ចផ្សេងៗរបស់ក្រុមហ៊ុនទាំងនេះ។

**ច. ការគ្រប់គ្រង ការត្រួតពិនិត្យ និងការតាមដានភ្នាក់ងារ/អ្នកចូលរួមក្នុងទីផ្សារមូលបត្រ**

ដើម្បីធានាបាននូវការគ្រប់គ្រង ការត្រួតពិនិត្យ និងការតាមដានភ្នាក់ងារ/អ្នកចូលរួមក្នុងទីផ្សារមូលបត្រ ប្រកបដោយប្រសិទ្ធភាព **ន.មូ.ក.** បាន និងបន្តតាមដាន និងត្រួតពិនិត្យការអនុវត្តកាតព្វកិច្ច, ចុះត្រួតពិនិត្យដល់ទីកន្លែង ឬតាមប្រព័ន្ធអនឡាញជាប្រចាំឆ្នាំ និងផ្តល់ការទទួលស្គាល់ដល់ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ (RTP), ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ (CSA) និងភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ (Custodian Agent)។

**៥.៣.១.៣. ចង្កោមសកម្មភាពទី៣÷ ការគាំពារវិនិយោគិនក្នុងវិស័យមូលបត្រ**

**ក. ការគ្រប់គ្រង និងការកសាងមូលដ្ឋានវិនិយោគិន**

ក្នុងទិសដៅក្នុងការគ្រប់គ្រង និងកសាងមូលដ្ឋានវិនិយោគិន **ន.មូ.ក.** បានដាក់ចេញនូវផែនការសកម្មភាពចម្បងដូចខាងក្រោម÷

- ផ្តល់លេខអត្តសញ្ញាណវិនិយោគិនតាមអនឡាញ
- តាមដានឃ្លាំមើលការវិនិយោគរបស់វិនិយោគិន
- រៀបចំ និងដាក់ឱ្យអនុវត្តប្រកាសស្តីពីការបង្កើតសមាគមវិនិយោគិនក្នុងវិស័យមូលបត្រ។

**ខ. កិច្ចគាំពារវិនិយោគិន និងការពង្រឹងការអនុវត្តច្បាប់ក្នុងវិស័យមូលបត្រ**

ក្នុងកិច្ចគាំពារវិនិយោគិន និងការពង្រឹងការអនុវត្តច្បាប់ក្នុងវិស័យមូលបត្រ **ន.មូ.ក.** បានដាក់ចេញនូវផែនការសកម្មភាពចម្បងដូចខាងក្រោម÷

- បង្កើតយន្តការ SERC Alert ដើម្បីជូនដំណឹង និងព័ត៌មាននានា ក្នុងគោលបំណងដាស់តឿនឱ្យសាធារណជនយកចិត្តទុកដាក់ និងប្រុងប្រយ័ត្នខ្ពស់ចំពោះសកម្មភាព និងប្រតិបត្តិការនានាដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ
- រៀបចំ និងដាក់ឱ្យអនុវត្តវិធានស្តីពីការផ្សះផ្សា និងការដោះស្រាយវិវាទ
- រៀបចំ និងដាក់ឱ្យអនុវត្តសៀវភៅណែនាំពាក់ព័ន្ធនឹងការពង្រឹងការអនុវត្តច្បាប់ និងការស៊ើបអង្កេតបទល្មើស និងអំពើល្មើសក្នុងវិស័យមូលបត្រ
- រៀបចំ និងដាក់ឱ្យអនុវត្តប្រកាសស្តីពី ការផាកពិន័យអន្តរការណ៍ និងទណ្ឌកម្មរដ្ឋបាលក្នុងវិស័យមូលបត្រ

- បន្តផ្សព្វផ្សាយពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មក្នុងវិស័យមូលបត្រ។

### ៥.៣.២. សកម្មភាពគាំទ្រការអភិវឌ្ឍស្ថាប័ន

#### ៥.៣.២.១. ចង្កោមសកម្មភាពទី១÷ ការពង្រឹង និងពង្រីកកិច្ចការស្រាវជ្រាវ និងការរៀបចំបទប្បញ្ញត្តិចាំបាច់បន្ថែម

**ក. លើកកម្ពស់ការស្រាវជ្រាវ និងជំរុញការអភិវឌ្ឍវិស័យមូលបត្រ**

ក្នុងការលើកកម្ពស់កិច្ចការស្រាវជ្រាវក្នុងវិស័យមូលបត្រ **ន.ម.ក.** បានដាក់ចេញនូវផែនការសកម្មភាពចម្បងដូចខាងក្រោម÷

- រៀបចំ និងដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមូលបត្ររយៈពេល ១០ ឆ្នាំ
- បន្តត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយពាក់ព័ន្ធវិស័យមូលបត្រ
- សិក្សា និងរៀបចំឯកសារស្រាវជ្រាវពាក់ព័ន្ធនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ក្របខណ្ឌបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងការគ្រប់គ្រង និងអភិវឌ្ឍវិស័យមូលបត្រ ព្រមទាំងការចុះបញ្ជី និងការជួញដូរប្រភេទមូលបត្រថ្មីៗបន្ថែមទៀត។

**ខ. សកម្មភាពគាំទ្រការគ្រប់គ្រង និងការត្រួតពិនិត្យអន្តរការីមូលបត្រ**

ក្នុងទិសដៅគាំទ្រការគ្រប់គ្រង និងការត្រួតពិនិត្យអន្តរការីមូលបត្រឱ្យមានប្រសិទ្ធភាព **ន.ម.ក.** បានដាក់ចេញនូវផែនការសកម្មភាពចម្បងដូចខាងក្រោម÷

- រៀបចំ និងដាក់ឱ្យអនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធនឹងការគ្រប់គ្រងប្រតិបត្តិការរបស់ក្រុមហ៊ុនអន្តរការីមូលបត្រ ដូចជា ការជួញដូរមូលបត្រតាមម៉ាជីន, ការកំណត់ឧបករណ៍តម្កល់ធានាអាជីវកម្មរបស់ក្រុមហ៊ុនអន្តរការីមូលបត្រ និងការជួញដូរទ្រព្យឌីជីថល
- រៀបចំ និងដាក់ឱ្យអនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធនឹងការផ្តល់អាជ្ញាបណ្ណ/ការអនុញ្ញាត និងការគ្រប់គ្រងក្រុមហ៊ុនអន្តរការីបន្ថែមទៀត ដូចជា ក្រុមហ៊ុនធ្វើអាជីវកម្មទ្រព្យឌីជីថល, ក្រុមហ៊ុនផ្តល់សេវាកាបូបទ្រព្យឌីជីថល, ក្រុមហ៊ុនធ្វើអាជីវកម្មហិរញ្ញប្បទានមូលបត្រ, ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ និងផ្គត់ផ្គង់បច្ចេកវិទ្យាព័ត៌មានក្នុងវិស័យមូលបត្រ និងក្រុមហ៊ុនចូលរួមក្នុងបរិស្ថានបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យមូលបត្រ។

### ៥.៣.២.២ ចង្កោមសកម្មភាពទី២៖ ការពង្រឹង និងពង្រីកការបណ្តុះបណ្តាល ព្រមទាំងការងារផ្សព្វផ្សាយ និងកិច្ចសហប្រតិបត្តិការ

#### ក. ការពង្រឹង និងពង្រីកការបណ្តុះបណ្តាល និងការងារផ្សព្វផ្សាយ

ក្នុងទិសដៅពង្រឹង និងពង្រីកការបណ្តុះបណ្តាល និងការងារផ្សព្វផ្សាយ **ន.ម.ក.** បានដាក់ចេញនូវផែនការសកម្មភាពចម្បងដូចខាងក្រោម៖

- បន្តរៀបចំវគ្គបណ្តុះបណ្តាលនិងការប្រឡង និងកម្មវិធីអប់រំវិជ្ជាជីវៈបន្តក្នុងវិស័យមូលបត្រ
- រៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា សន្និសីទ សម្រាប់ក្រុមហ៊ុនបោះផ្សាយ ក្រុមហ៊ុនបោះផ្សាយសក្តានុពល វិនិយោគិនសក្តានុពល និងសាធារណជន
- រៀបចំ និងផ្សព្វផ្សាយរបាយការណ៍សមិទ្ធផលប្រចាំឆ្នាំ ព្រឹត្តិបត្រមូលបត្រ ព្រឹត្តិបត្រទិន្នន័យជួញដូរ ព្រឹត្តិបត្រវិនិយោគិននិងការវិនិយោគ ពុទ្ធិមូលបត្រ ព្រមទាំងអត្ថបទនិងវីដេអូផ្សព្វផ្សាយផ្សេងៗ។

#### ខ. ការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការ

ក្នុងទិសដៅពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការទាំងក្នុង និងក្រៅប្រទេស **ន.ម.ក.** បានដាក់ចេញនូវផែនការសកម្មភាពចម្បងដូចខាងក្រោម៖

- ទទួលធ្វើជាប្រធានវេទិកាទីផ្សារមូលធនអាស៊ាន
- ទទួលធ្វើជាម្ចាស់ផ្ទះរៀបចំសន្និសីទអន្តរជាតិក្នុងក្របខណ្ឌវេទិកាទីផ្សារមូលធនអាស៊ាន
- បន្តនីតិវិធីស្នើសុំចូលជាសមាជិកពេញសិទ្ធិនៃអង្គការគណៈកម្មការមូលបត្រអន្តរជាតិ (International Organization of Securities Commissions-IOSCO)
- ចុះ និងជំរុញការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នាជាមួយវិស័យឯកជន ស្ថាប័នសាធារណៈ និយ័តករបរទេស និងដៃគូអភិវឌ្ឍន៍ផ្សេងៗ
- ចូលរួមរៀបចំកម្មវិធីបណ្តុះបណ្តាលកសាងសមត្ថភាពសម្រាប់សមាជិកវេទិកាទីផ្សារមូលធនអាស៊ាន
- ផ្តល់កិច្ចសហការក្នុងការផ្តល់មតិយោបល់ និងធាតុចូលដល់ការរៀបចំបទប្បញ្ញត្តិ ឯកសារយុទ្ធសាស្ត្រ ឬស្តង់ដានានាដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ **ន.ម.ក.**
- បន្តចូលរួមកិច្ចប្រជុំកម្រិតជាតិ កម្រិតតំបន់ និងអន្តរជាតិនានាដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ **ន.ម.ក.**។

តារាងផែនការសកម្មភាពប្រចាំឆ្នាំលម្អិតនៃផែនការអភិវឌ្ឍស្ថាប័នសម្រាប់រយៈពេល ៥ ឆ្នាំ (២០២១-២០២៥) របស់ **ន.ម.ក.** មានកំណត់ក្នុងផ្នែកទី៨ ខាងក្រោមនេះ។

## ៦. យន្តការត្រួតពិនិត្យ និងការវាយតម្លៃ

### ៦.១. ស្ថាប័នទទួលបន្ទុក

